# ការបែងចែកក្រុមពិភាក្សា
# សម្រាប់
# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ
# ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃ
# ផែនការយុទ្ធសាស្ត្រជាតិរយៈពេល ៥ឆ្នាំ (២០១៩-២០២៣)
# ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (តាមប្រព័ន្ធអនឡាញ)

ថ្ងៃព្រហស្បតិ៍-សុក្រ ១៣-១៤ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី ២២-២៣ ខែកក្កដា ឆ្នាំ ២០២១

## ការពិភាក្សាក្រុមទី១៖ ក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

ការពិភាក្សាផ្តោតលើបទពិសោធន៍ល្អ និងភាពប្រឈមនានាក្នុងវិធីសាស្ត្រនីមួយៗ ដែលបានអនុវត្តន៍សម្រាប់ការងារ បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងក្រុមគោលដៅខុសៗគ្នា (សហគមន៍ដែលងាយរងគ្រោះ យុវវ័យ និងកុមារក្នុងសាលារៀន យុវវ័យ និងកុមារក្នុងសហគន៍ ក្រុមជនទេសន្តរប្រវេសន៍ ដែលវិលត្រឡប់ ក្រុមស្ត្រីវ័យក្មេង អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ...) ការប៉ាន់ប្រមាណពីវិធីដោះស្រាយ ជាពិសេសក្នុងដំណាក់កាលនៃការរាតត្បាតដោយកូវីដ-១៩ និងផលប៉ះពាល់ក្នុងរង្វង់ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដែលអាចធ្វើឲ្យការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សមានប្រសិទ្ធភាព ។

សមាសភាពក្រុមពិភាក្សាទី១

- ក្រសួង ស្ថាប័ន

  ១- តំណាងក្រសួងអប់រំយុវជន និងកីឡា
  
  ២-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  
  ៣-តំណាងក្រសួងទេសចរណ៍
  
  ៤-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ
  
  ៥-តំណាងក្រសួងព័ត៌មាន
  
  ៦-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  
  ៧-តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន
  
  ៨-តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  
  ៩-តំណាងក្រសួងផែនការ
  
  ១០-តំណាងក្រសួងធម្មការ និងសាសនា
  
  ១១-តំណាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
  
  ១២-តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
  
  ១៣-តំណាងក្រសួងមុខងារសាធារណៈ

១៤-តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ
១៥-តំណាងទីចាត់ការការងារព្រំដែន ក្រសួការពារជាតិ
១៦-តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
១៧-តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍
១៨-តំណាងអគ្គលេខាធិការដ្ឋាន គជបជ (ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់)
១៩-តំណាងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
២០-តំណាងលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

● រាជធានី-ខេត្ត

សូមគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត ចាត់តាំងមន្ត្រីជំនាញដែលពាក់ព័ន្ធការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ចូលរួមកិច្ចពិភាក្សាជាមួយប្រធានបទខាងលើនេះ ។

**សំណួរពិភាក្សា សម្រាប់ក្រុមទី១ ៖**

១.តើអំពើជួញដូរមនុស្ស មានរូបភាពដូចម្តេចខ្លះ ក្នុងអំឡុងពេលកូវីដ-១៩ ឬអាចនឹងកើតមានក្រោយកូវីដ-១៩ ?
២.តើក្រុមគោលដៅណាខ្លះ ដែលជាអាទិភាពសម្រាប់ការងារបង្ការទប់ស្កាត់ អំពើជួញដូរមនុស្សក្នុងដំណាក់កាលនេះ?
៣.តើក្រុមគោលដៅណាខ្លះ ដែលចាំបាច់ត្រូវចាត់ទុកជាអាទិភាពក្នុងសកម្មភាពបង្ការទប់ស្កាត់?
៤.តើវិធីសាស្ត្រណាខ្លះ ដែលចាំបាច់ត្រូវប្រើ និងបានប្រើសម្រាប់ធ្វើការបង្ការទប់ស្កាត់ដោយប្រសិទ្ធភាព?
៥.តើសកម្មភាពបង្ការទប់ស្កាត់ណាខ្លះដែលមិនអាចធ្វើបាន ក្នុងអំឡុងពេល កូវីដ-១៩? ឬអាចផ្លាស់ប្តូរវិធីសាស្ត្រដូចម្តេច?
៦.តើកុមារត្រូវបានទទួលនូវកិច្ចការពារដូចម្តេចខ្លះ ដើម្បីបង្ការទប់ស្កាត់ពីភាពរងគ្រោះ ពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ច និងអំពើជួញដូរមនុស្ស? (ឧទាហរណ៍ កុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ កុមារដែលរងការរំលោភបំពានផ្លូវភេទ កុមាររងអំពើហិង្សាធ្ងន់ធ្ងរ ...។ល។)
៧.តើការធ្វើអធិការកិច្ច កន្លងមករកឃើញភាពខុសឆ្គងរបស់ក្រុមហ៊ុនឯកជន ដែលប្រព្រឹត្តខុសពីគោលការណ៍ ឬច្បាប់កំណត់ ត្រូវបានដាក់វិធានការ ឬចំណាត់ការដូចម្តេច? កន្លងមកបានប៉ុន្មានក្រុមហ៊ុន (ឧទាហរណ៍ក្រុមហ៊ុនជ្រើសរើសពលករ ក្រុមហ៊ុនឡានដឹក ....) ?
៨.ដោយហេតុថា អំពើជួញដូរមនុស្ស មួយចំនួនធំ ត្រូវបានរកឃើញ ក្នុងចំណោមជនដែលធ្វើទេសន្តរប្រវេសន៍ តើក្រសួងស្ថាប័ន និងអង្គភាពណាខ្លះ ដែលបាន និងកំពុងធ្វើការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការជួញដូរពលកម្ម អំពើពោះជំនួស(តាមរូបភាពផ្សេងៗ) ការស្វែងរកគូស្រករក្រៅប្រទេស ដោយប្រថុយប្រថាន ... ជាដើមនោះ? តើស្ថាប័នណាទៀត ដែលអាចចូលរួមបន្ថែមទៀត?
៩.តើការពង្រឹងកិច្ចសហការកន្លងមក ទាំងរវាងស្ថាប័នពាក់ព័ន្ធ ទាំងរវាងប្រទេសពាក់ព័ន្ធ មានចំណុចខ្វះចន្លោះអ្វីខ្លះ បានជាមិនអាចបញ្ឈប់លំហូរទេសន្តរប្រវេសន៍ដោយប្រថុយប្រថានបាន?

១០.តើមូលហេតុអ្វីខ្លះ ដែលនាំឲ្យពលរដ្ឋកម្ពុជា មានទំនោរចាកចេញទៅក្រៅប្រទេស ទាំងដឹងច្បាស់ថា នឹងមានគ្រោះថ្នាក់ មិនទទួលបានផលប្រយោជន៍តាមការរំពឹងទុក ប្រឈមបញ្ហាខុសច្បាប់ជាដើមនោះ?

១១.តើត្រូវប្រើប្រាស់វិធីសាស្ត្របែបណា ច្បាប់ណា ឬវិធានការរបៀបណាខ្លះ ទើបអាចកាត់បន្ថយ ឈានទៅលុបបំបាត់សកម្មភាពប្រថុយប្រថានទាំងនោះបាន និងអាចការពារអាយុជីវិត សិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍?

១២.តើអង្គការដៃគូ មានភារកិច្ចចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងសកម្មភាពណាខ្លះ របៀបណាខ្លះ ដើម្បីរួមចំណែកឲ្យការងារបង្ការទប់ស្កាត់ទទួលបានប្រសិទ្ធភាព និង ប្រសិទ្ធផល? ...................................

---

សូមរក្សាសិទ្ធក្នុងការកែប្រែក្នុងករណីចាំបាច់

## ការពិភាក្សាក្រុមទី២៖ ការងារអនុវត្តច្បាប់ យុត្តិធម៌ព្រហ្មទណ្ឌ (ការស៊ើបអង្កេត បង្ក្រាប សង្គ្រោះ និងផ្តន្ទាទោស)

កិច្ចពិភាក្សា នឹងផ្តោតលើបទពិសោធន៍ ភាពប្រឈមក្នុងដំណាក់កាលនីមួយៗ នៃការអនុវត្តនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ ដែលបានអនុវត្តកន្លងមក រួមមានទាំងការស្រាវជ្រាវរកជនប្រព្រឹត្តបទល្មើស ការបង្ក្រាប ការសង្គ្រោះជនរងគ្រោះ ការបញ្ជូនជនរងគ្រោះ ការអនុវត្តនីតិវិធីតុលាការ ការឃុំគ្រងជនក្រៅឃុំ កិច្ចសហការក្នុងការអនុវត្តនីតិវិធីស្វែងរកជនល្មើស ការបង្ក្រាប និងការអនុវត្តនីតិវិធីតុលាការ ក្នុងការផ្តន្ទាទោសជនល្មើសនៅក្រៅដែនដី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យជនល្មើសពិតប្រាកដ និងអ្នកពាក់ព័ន្ធបានទទួលការផ្តន្ទាទោសត្រឹមត្រូវតាមច្បាប់កំណត់ ជនរងគ្រោះទទួលបានយុត្តិធម៌ និងទទួលបានសំណងសមស្រប ដែលធ្វើឲ្យប្រជាពលរដ្ឋមានទំនុកចិត្ត និងភាពកក់ក្តៅ ហើយគោរពកោតខ្លាចច្បាប់ មិនហ៊ានប្រព្រឹត្តខុសច្បាប់ ។ ទន្ទឹមនឹងនោះ គប្បីប្រមើលមើលអំពីវិធីសាស្ត្រថ្មីៗ ដែលនាំឲ្យមានការចូលរួមកាន់តែច្រើនពីប្រជាពលរដ្ឋ ក្នុងការរកមុខរកជនប្រព្រឹត្តបទល្មើសជួញដូរមនុស្ស កិច្ចសហការកាន់តែប្រសើររវាង មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីសង្គមកិច្ច និងតុលាការ ក៏ដូចជា ជាមួយអង្គការដៃគូពាក់ព័ន្ធ និងជនរងគ្រោះផ្ទាល់ ដើម្បីបង្កើនប្រសិទ្ធភាពដល់ការអនុវត្តច្បាប់ ជាពិសេសក្នុងដំណាក់កាលនៃការរាតត្បាតដោយកូវីដ-១៩ និងផលប៉ះពាល់ក្នុងរង្វង់ ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដែលអាចធ្វើឲ្យការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សមានប្រសិទ្ធភាព ។

សមាសភាពក្រុមពិភាក្សាទី២ ៖

- ក្រសួង ស្ថាប័ន

  ១-តំណាងក្រសួងយុត្តិធម៌
  ២-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  ៣-តំណាងក្រសួងការពារជាតិ
  ៤-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី
  ៥-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  ៦-តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន
  ៧-តំណាងក្រសួងព័ត៌មាន
  ៨-តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  ៩-តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ
  ១០-តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (ក្រុមជំនួយកិច្ចការយុត្តិធម៌ និងក្រុមជំនួយកិច្ចការអនុវត្តច្បាប់)
  ១១-តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស
  ១២-តំណាងទីចាត់ការការងារព្រំដែន
  ១៣-តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
  ១៤-តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍

● រាជធានី-ខេត្ត

សូមគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត ចាត់តាំងមន្ត្រីជំនាញដែលពាក់ព័ន្ធចូលរួមកិច្ចពិភាក្សាជាមួយប្រធានបទខាងលើនេះ ។

**សំណួរពិភាក្សាសម្រាប់ក្រុមទី២ ៖**

១. តើការស៊ើបអង្កេត ការបង្ក្រាប និងការកំណត់អត្តសញ្ញាណជនរងគ្រោះ កន្លងមក មានចំណុចងាយស្រួល និងភាពប្រឈមអ្វីខ្លះ ជាពិសេស ក្នុងដំណាក់កាលនៃការរាតត្បាតដោយជំងឺកូវីដ-១៩ ?

២. តើជនរងគ្រោះ បានផ្តល់កិច្ចសហការល្អ ក្នុងការផ្តល់សក្ខីកម្ម និងព័ត៌មានត្រឹមត្រូវសម្រាប់ការស្វែងរកបទល្មើស និងជនល្មើសដែរឬទេ ? ព្រោះអ្វី ?

៣. តើអ្វីទៅជាដំណោះស្រាយ ដែលឈានដល់ការបង្ក្រាបបានជោគជ័យកន្លងមក ?

៤. ក្នុងការស្វែងរក និងបង្ក្រាបជនល្មើសដែលកំពុងនៅបរទេស ឬបានគេចខ្លួនទៅបរទេស តើការអនុវត្តនីតិវិធីដែលពាក់ព័ន្ធនឹងកិច្ចសហការ ត្រូវបានអនុវត្តតាមកិច្ចព្រមព្រៀង ឬអនុស្សរណៈដែរឬទេ? តើនៅមានចំណុចប្រឈមអ្វីខ្លះទៀត ?

៥. តើគួរ ឬត្រូវមាននីតិវិធី ឬវិធីសាស្ត្រណាទៀតដែលមានប្រសិទ្ធភាពជាងនេះ ? តើត្រូវមានកិច្ចសហការពី ស្ថាប័ន អង្គភាព ឬសមត្ថកិច្ចណាខ្លះ ដើម្បីជំរុញការអនុវត្តនេះឲ្យរឹតតែមានប្រសិទ្ធភាពខ្ពស់ ?

៦. ក្នុងប្រតិបត្តិការរុករកបទល្មើសក្នុងវិស័យឯកជនដែលពាក់ព័ន្ធ ឧទាហរណ៍ ទីភ្នាក់ងារជ្រើសរើសឯកជនដែលអនុវត្តខុសច្បាប់ បណ្តាញមេខ្យល់នាំមនុស្សចេញឆ្លងដែនខុសច្បាប់ ក្រុមហ៊ុនដែលប្រើប្រាស់កម្មករខុសច្បាប់ (អាចពាក់ព័ន្ធនឹងជនបរទេស ឬអនីតិជន) ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬពលកម្មកុមារ ក្នុងទម្រង់ធ្ងន់ធ្ងរ ជាដើម តើមានឧបសគ្គ ឬភាពប្រឈមអ្វីខ្លះ ដែលត្រូវដោះស្រាយ? ដោយប្រើប្រាស់នូវវិធានការច្បាប់ណា? ឬកិច្ចសហការបែបណា? ឬត្រូវដោះស្រាយដោយស្ថាប័នកម្រិតណា ទើបអាចមានប្រសិទ្ធភាព ?

៧. តើនីតិវិធីបញ្ជូន ឬការរក្សា ជនសង្ស័យ ឬជនរងគ្រោះសម្រាប់ដំណាក់កាលនៃនីតិវិធីតុលាការ កន្លងមក ជួបប្រទះនឹងការលំបាក ឬភាពប្រឈមអ្វីខ្លះ? តើគួរមានដំណោះស្រាយដូចម្តេច? ពាក់ព័ន្ធនឹងបទដ្ឋានច្បាប់អ្វីខ្លះ? ពាក់ព័ន្ធនឹងសមត្ថកិច្ចណាខ្លះ ?

៨. ព្រះរាជអាជ្ញា និងតុលាការ ត្រូវការកិច្ចសហការពីអង្គភាព សមត្ថកិច្ច ឬស្ថាប័នណាខ្លះ ដើម្បីសម្រួល និងពន្លឿននីតិវិធីនៃការផ្តន្ទាទោសឲ្យកាន់តែប្រសើរឡើង ?

៩. តើការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ អាចមានផលប្រយោជន៍ ដល់ការផ្តល់នូវព័ត៌មានជាបុរេវិនិច្ឆ័យសម្រាប់ការពិចារណាដល់ការប្រើប្រាស់ជាបង្អែក នៃការពិចារណារបស់តុលាការដែរឬទេ? តើធ្វើដូចម្តេចទើបព័ត៌មានដែលបានមកពីការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ អាចត្រូវបានទទួលស្គាល់ថាមានប្រយោជន៍ដល់ដំណើរការផ្តន្ទាទោសជនល្មើសនិងដល់ការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ

១០.តើអង្គការមិនមែនរដ្ឋាភិបាល មានតួនាទីអ្វីខ្លះ ក្នុងការជួយដល់ដំណើការរឿងក្តីជួញដូរមនុស្ស និងក្នុងនីតិវិធីតុលាការ ? ..................................

---

សូមរក្សាសិទ្ធក្នុងការកែប្រែក្នុងករណីចាំបាច់

## ការពិភាក្សាក្រុមទី៣៖ ការធានាសហប្រតិបត្តិការអន្តរជាតិ ប្រឆាំងអំពើជួញដូរមនុស្ស និង ការគ្រប់គ្រងលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន

កិច្ចពិភាក្សា នឹងផ្តោតលើបទពិសោធន៍ល្អ និងភាពប្រឈមក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និង សមត្ថកិច្ចប្រទេសពាក់ព័ន្ធ ក៏ដូចជាការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស និងនីតិវិធីប្រតិបត្តិស្តង់ដានានា ដែលបានចុះហត្ថលេខាកន្លងមក ក្នុងការបង្ការទប់ស្កាត់ លំហូរពលករដែលមិនប្រក្រតី ការស៊ើបអង្កេត ការបង្ក្រាបបទល្មើសជួញដូរមនុស្ស កិច្ចសហការជាមួយអាជ្ញាធរបរទេស ក្នុងការសង្គ្រោះជនរងគ្រោះ និងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅក្រៅប្រទេស និតិវិធី និងកិច្ចសហការក្នុង ការបញ្ជូនជនរងគ្រោះ ដើម្បីធ្វើមាតុភូមិនិវត្តន៍ ការបញ្ជូន និងទទួលពលករវិលត្រឡប់ និងបញ្ជូនត្រឡប់ដោយ អាជ្ញាធរបរទេស នីតិវិធីរដ្ឋបាល តាមប្រព័ន្ធការទូត កិច្ចសហការក្នុងការគ្រប់គ្រងលំហូរពលករ មិនប្រក្រតីឆ្លងកាត់ព្រំដែន...។ល។ ប្រមើលមើលអំពីដំណោះស្រាយដែលនាំឲ្យកិច្ចសហការរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសពាក់ព័ន្ធ ក្នុងការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ មិនប្រក្រតីឆ្លងកាត់ព្រំដែន នីតិវិធីបញ្ជូន និងទទួលពលករដែលអាចគ្រប់គ្រងបាន ការរួមគ្នាប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពលើពលករកម្ពុជា ទាំងក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងប្រទេសគោលដៅ នៅគ្រប់ដំណាក់កាលក្នុងវដ្តនៃទេសន្តរប្រវេសន្តរប្រវេសន៍ បានកាន់តែល្អប្រសើរ ជាពិសេសក្នុងដំណាក់កាលនៃការរាតត្បាតដោយកូវីដ-១៩ និងផលប៉ះពាល់ក្នុង រង្វង់ ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដែលអាចធ្វើឲ្យការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងកិច្ចការពារពលករទេសន្តរប្រវេសន៍ មានប្រសិទ្ធភាពខ្ពស់ ។

សមាសភាពភាពក្រុមពិភាក្សាទី៣ ៖

- ក្រសួង ស្ថាប័ន
  - ១-តំណាងក្រសួងកិច្ចការនារី
  - ២-តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  - ៣-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  - ៤-តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន
  - ៥-តំណាងក្រសួងព័ត៌មាន
  - ៦-តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  - ៧-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - ៨-តំណាងក្រសួងសុខាភិបាល
  - ៩-តំណាងក្រសួងការពារជាតិ
  - ១០-តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ
  - ១១-តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ និង ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍)
  - ១២-តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៣-តំណាងទីចាត់ការការងារព្រំដែន
១៤-តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
១៥-តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍

● រាជធានី-ខេត្ត

សូមគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត ចាត់តាំងមន្ត្រីជំនាញដែលពាក់ព័ន្ធនឹងការងារព្រំដែន និងកិច្ចសហប្រតិបត្តិការទ្វេភាគី ចូលរួមកិច្ចពិភាក្សាជាមួយប្រធានបទខាងលើនេះ ។

**សំណួរពិភាក្សាសម្រាប់ក្រុមទី៣ ៖**

១. ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺ កូវីដ-១៩ តើកិច្ចសហប្រតិបត្តិការរវាងសមត្ថកិច្ច និងអាជ្ញាធរព្រំដែនកម្ពុជា និងប្រទេសជិតខាង មានភាពប្រឈមអ្វីខ្លះ ពាក់ព័ន្ធការគ្រប់គ្រងលំហូរមិនប្រក្រតីនៃពលករឆ្លងកាត់ព្រំដែន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស?

២. តើមានប្រភេទនៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចអ្វីខ្លះ ដែលកើតមានក្នុងដំណាក់កាលនៃការរាតត្បាតជំងឺកូវីដ-១៩ នេះ? (ក្នុងប្រទេស និងនៅក្រៅប្រទេស)

៣. តើមានវិធានការអ្វីខ្លះដើម្បីបង្ការទប់ស្កាត់សកម្មភាពជួញដូរមនុស្សឆ្លងដែនដែរឬទេ (ឧទាហរណ៍ ការនាំស្ត្រីវ័យក្មេងចេញឆ្លងដែនដោយខុសច្បាប់ ដើម្បីរកគូស្រករដោយប្រថុយប្រថាននៅក្រៅប្រទេស ការនាំពលករឆ្លងដែន ក្នុងពេលមានការរឹតបន្តឹង ឬបិទព្រំដែន)?

៤. តើអាជ្ញាធរកណ្តាលកន្លងមក ត្រូវបានប្រើប្រាស់ដើម្បីការដោះស្រាយ រឿងក្តីជួញដូរមនុស្សឆ្លងដែនដែរឬទេ? តើមានភាពប្រឈមអ្វីខ្លះ ក្នុងការប្រើប្រាស់យន្តការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងរឿងក្តីព្រហ្មទណ្ឌជាមួយប្រទេសក្នុងតំបន់? តើគួរពង្រឹងដូចម្តេច?

៦. តើកិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាន ស្តីពីយន្តការអនុវត្តច្បាប់ រវាងប្រទេសកម្ពុជា និងប្រទេសគោលដៅ ដូចជាថៃ ឥណ្ឌូនេស៊ី វៀតណាម ម៉ាឡេស៊ី និងចិន ប្រព្រឹត្តទៅដូចម្តេច? ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ តើការជួយជនរងគ្រោះនៅឯបរទេសឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ មានភាពប្រឈមដូចម្តេចខ្លះ? តើត្រូវកែលម្អ ឬពង្រឹងដូចម្តេច?

៧. តើការរាតត្បាតនៃជំងឺកូវីដ-១៩ មានផលប៉ះពាល់ដល់ការស្វែងរកអត្តសញ្ញាណជនរងគ្រោះជាពិសេស អ្នកដែលបានស្លាប់នៅក្រៅប្រទេស ដើម្បីដោះស្រាយនីតិវិធីច្បាប់ និងសំណងយ៉ាងណាខ្លះ?

៨. តើមានកិច្ចសហប្រតិបត្តិការរវាង ស្ថានតំណាង និងសមត្ថកិច្ចប្រទេសគោលដៅ ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែរឬទេ? មានការឯកភាពគ្នាក្នុងនីតិវិធីឬទេ?

៩. តើនីតិវិធីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ មានភាពប្រឈមអ្វីខ្លះ? តើគួរកែលម្អនិងពង្រឹងដូចម្តេច?

១០. ក្រៅពីការបញ្ជូនជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ តើមានដំណោះស្រាយសម្រាប់ការស្រាវជ្រាវបទល្មើស ឬនីតិវិធីផ្លូវច្បាប់ដទៃទៀត ក្នុងប្រទេសគោលដៅអ្វីខ្លះ? តើមានភាពប្រឈមអ្វីខ្លះ? តើគួរមានដំណោះស្រាយដូចម្តេច?

១១. តើមានភាពប្រឈមអ្វីខ្លះ ក្នុងការគ្រប់គ្រងលំហូរមិនប្រក្រតី របស់ពលករឆ្លងកាត់ព្រំដែន? តើធ្វើដូចម្ដេចដើម្បីដោះស្រាយភាពប្រឈមនេះ ជាពិសេសក្នុងដំណាក់កាលនៃការរាតត្បាតនៃជំងឺកូវីដ-១៩?

១២. តើលោកអ្នកយល់ថា មណ្ឌលទទួលពលករនៅព្រំដែន មានតួនាទីសំខាន់ ក្នុងការចូលរួមទប់ស្កាត់លំហូរមិនប្រក្រតីឆ្លងកាត់ព្រំដែនរបស់ពលករ និងការស្រាវជ្រាវរកអត្តសញ្ញាណជនរងគ្រោះ បានកម្រឹតណា? អង្គភាពស្ថាប័នណាខ្លះ ដែលអាចប្រើប្រាស់មណ្ឌលសម្រាប់ជាកិច្ចសហប្រតិបត្តិការក្នុងការបង្ការ ទប់ស្កាត់អំពើជួញដូរ ពលករ និងការកេងប្រវ័ញ្ចក្នុងវដ្តនៃទេសន្តរប្រវេសន៍? ដូចម្ដេច?

---

សូមរក្សាសិទ្ធក្នុងការកែប្រែក្នុងករណីចាំបាច់

## ការពិភាក្សាក្រុមទី៤៖ ការងារការពារជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

កិច្ចពិភាក្សា នឹងផ្តោតលើបទពិសោធន៍ល្អ ក្នុងការងារការពារជនរងគ្រោះ ដែលមានវិធីសាស្ត្រខុសៗគ្នា រវាងជនរងគ្រោះជាកុមារ (កុមារី កុមារា) យុវវ័យ (ស្ត្រី បុរស) មនុស្សពេញវ័យ និងមនុស្សចាស់ (ស្ត្រី និងបុរស) ស្ត្រីដែលមានកូនតាមខ្លួន ជនមានពិការភាព និងជនមានស្មារតីវិបល្លាស អ្នកជំងឺ អ្នកមានផ្ទុកមេរោគ កូវីដ-១៩ ...។ល។ ក្នុងដំណាក់កាលនីមួយៗ ចាប់តាំងពីការទទួលជនរងគ្រោះ កំណត់អត្តសញ្ញាណជនរងគ្រោះបឋម ការផ្តល់សេវា ការបញ្ជូនទៅគោលដៅផ្តល់សេវា កិច្ចសហប្រតិបត្តិការក្នុងការផ្តល់សេវាតាមប្រភេទនៃសេវា ការតាមដានស្ថានភាពជនរងគ្រោះ ការប៉ាន់ប្រមាណស្ថានភាពគ្រួសារ ការរក្សាទុក និងថែទាំជនរងគ្រោះក្នុងមណ្ឌលសុវត្ថិភាព ការធ្វើសមាហរណកម្មជនរងគ្រោះនៅក្នុងសហគមន៍ ការស្តារនីតិសម្បទា កិច្ចការពារជនរងគ្រោះ ក្នុងដំណើរការនីតិវិធីតុលាការ ការធ្វើមាតុភូមិនិវត្តន៍ កិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធ និងរវាងអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ និងរវាងអាជ្ញាធរ និងសមត្ថកិច្ចប្រទេសពាក់ព័ន្ធ...។ល។ ភាពប្រឈមក្នុងដំណាក់កាលនីមួយៗ ភាពប្រឈមក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ក៏ដូចជាការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀង ស្តីពីកិច្ចសហការប្រឆាំងការជួញដូរមនុស្ស និងនីតិវិធីប្រតិបត្តិស្តង់ដានានា ដែលបានចុះហត្ថលេខាកន្លងមក ក្នុងការសង្គ្រោះ ការបញ្ជូន និងការទទួលជនរងគ្រោះ និងការផ្តល់កិច្ចការពារជនរងគ្រោះរវាងប្រទេសពាក់ព័ន្ធ ការអនុវត្តនីតិវិធីតុលាការ ដើម្បីជនរងគ្រោះទទួលបានយុត្តិធម៌ ការអនុវត្តបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ក្នុងចំណោមពលករវិលត្រឡប់ ឬបញ្ជូនត្រឡប់ នីតិវិធីបញ្ជូន និងការផ្តល់សេវា...។ល។ ប្រមើលមើលអំពីដំណោះស្រាយ ដែលនាំឲ្យកិច្ចសហការរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសពាក់ព័ន្ធក្នុងការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍ និងការប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាពលើពលករកម្ពុជាបានកាន់តែល្អប្រសើរ ជាពិសេសក្នុងដំណាក់កាលនៃការរាតត្បាតកូវីដ-១៩ និងផលប៉ះពាល់ក្នុងរង្វង់ ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដែលអាចធ្វើឲ្យការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងកិច្ចការពារពលករទេសន្តរប្រវេសន៍ មានប្រសិទ្ធភាពខ្ពស់ក្នុងវដ្តនៃទេសន្តរប្រវេសន៍ ។

សមាសភាពក្រុមពិភាក្សាទី៤

- ក្រសួង ស្ថាប័ន

  ១-តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  ២-តំណាងក្រសួងកិច្ចការនារី
  ៣-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  ៤-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  ៥-តំណាងក្រសួងសុខាភិបាល
  ៦-តំណាងក្រសួងព័ត៌មាន
  ៧-តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  ៨-តំណាងក្រសួងផែនការ
  ៩-តំណាងក្រសួងធម្មការ និងសាសនា

១០-តំណាងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
១១-តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
១២-តំណាងក្រសួងទេសចរណ៍
១៣-តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ(ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ )
១៤-តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម
១៥-តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍
១៦-តំណាងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
១៧-តំណាងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
១៨-តំណាងលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

● រាជធានី-ខេត្ត

សូមគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត ចាត់តាំងមន្ត្រីជំនាញដែលពាក់ព័ន្ធចូលរួមកិច្ចពិភាក្សាជាមួយប្រធានបទខាងលើនេះ ។

**សំណួរពិភាក្សាសម្រាប់ក្រុមទី៤ ៖**

១. តើអង្គភាពស្ថាប័នដែលធ្វើការផ្តល់សេវាជួយជនរងគ្រោះ បានអនុវត្តគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះបឋមដែរឬទេ? តើមានការលំបាក ភាពប្រឈម និងចំនុចខ្វះខាតអ្វីខ្លះដែលត្រូវកែលម្អ ក្នុងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ការបញ្ជូន និងការផ្តល់សេវា?
២. តើកិច្ចសហការក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះពីក្រៅប្រទេស មានការប្រឈមអ្វីខ្លះ? នៅក្នុងដំណាក់កាលណា? ដូចម្តេច?
៣. តើមានសេវាប្រភេទណាខ្លះ (ក្រៅពីអំណោយ) ដែលបានផ្តល់ជូនជនរងគ្រោះ នៅតាមមណ្ឌលថែទាំជនរងគ្រោះ និងនៅតាមសហគមន៍?
៤. តើការផ្តល់ជំនាញវិជ្ជាជីវៈ ប្រភេទណាដែលជនរងគ្រោះ (បុរស ស្ត្រី យុវវ័យ) អាចយកទៅប្រើប្រាស់ជាប្រយោជន៍ ក្នុងការលើកកម្ពស់ជីវភាព ដើម្បីកាត់បន្ថយភាពរងគ្រោះជាថ្មី ដោយអំពើជួញដូរមនុស្ស?
៥. តើកត្តាអ្វីខ្លះដែលជំរុញ ឬអូសទាញជនរងគ្រោះ ឲ្យប្រថុយប្រថានវិលត្រឡប់ទៅរកភាពរងគ្រោះជាថ្មី?
៦. តើកត្តាអ្វីខ្លះ ដែលជំរុញ ឬអូសទាញប្រជាពលរដ្ឋ ជាពិសេស យុវវ័យ ឲ្យជឿតាមការអូសទាញរបស់មេខ្យល់ និងប្រថុយប្រថាន នឹងភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច?
៧. តើមានវិធីសាស្ត្រអាចយកឈ្នះមេខ្យល់បានឬទេ? របៀបណា?
៧. តើការអនុវត្តនីតិវិធីតុលាការដើម្បីជនរងគ្រោះទទួលបានយុត្តិធម៌និងសំណង មានភាពប្រឈមអ្វីខ្លះ?
៨. តើនៅក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ ការកំណត់អត្តសញ្ញាណជនងរងគ្រោះ (ជាពិសេសការសម្ភាសន៍) និងការផ្តល់សេវាជូនជនរងគ្រោះ អាចអនុវត្តន៍បានដោយរលូនដែរឬទេ? តើមានវិធីសាស្ត្រអ្វីខ្លះដែលធ្វើឲ្យការផ្តល់សេវា អាចប្រព្រឹត្តបានល្អប្រសើរ?

៩. តើការអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀង និងនីតិវិធីនៃការប្រតិបត្តិបទដ្ឋាន ជាមួយប្រទេសពាក់ព័ន្ធកន្លងមក មានឧបសគ្គ ឬភាពប្រឈមអ្វីខ្លះ ជាពិសេសក្នុងដំណាក់កាលកូវីដ-១៩?

១០. តើមានភាពប្រឈមអ្វីខ្លះ ក្នុងកិច្ចសហការបញ្ជូនជនរងគ្រោះទៅធ្វើសមាហរណកម្មនៅសហគមន៍ តាមបណ្តារាជធានី-ខេត្ត?

១១. តើមានវិធីសាស្រ្ត ឬឧបករណ៍អ្វីខ្លះ ក្នុងការតាមដានស្ថានភាពរបស់ជនរងគ្រោះក្នុងអំឡុងពេល នៃការផ្តល់សេវា?

១២. តើការតាមដានជនរងគ្រោះ ដែលពាក់ព័ន្ធនឹងនីតិវិធីដាក់ជនត្រូវចោទឲ្យនៅក្រៅឃុំ ធ្វើបានដូចម្តេច? មានភាពប្រឈមដូចម្តេចខ្លះ?

១៣. តើសមត្ថកិច្ចណាខ្លះ ដែលត្រូវតាមឃ្លាំមើល ជនត្រូវចោទដែលត្រូវបានដាក់ឲ្យនៅក្រៅឃុំ? តើសហការគ្នាដូចម្តេច ដើម្បីធានាថា ជននោះ មិនបានគម្រាមកំហែងជនរងគ្រោះ ឬគេចខ្លួន?

---

សូមរក្សាសិទ្ធក្នុងការកែប្រែក្នុងករណីចាំបាច់